Post Office Box 9103
Van Nuys, California 91409-9103

បញ្ជីពាក្យខុសនៃសៀវភៅណែនាំរបស់សមាជិក **Health Net Community Solutions (Health Net)**

មានការផ្លាស់ប្តូរទៅលើសៀវភៅណែនាំសមាជិករបស់លោកអ្នកដែលបានពិពណ៌នានៅក្នុងបញ្ជីពាក្យខុសនេះ។ ភាសាដែលបានបង្ហាញនៅខាងក្រោមឥឡូវនេះ គឺជាផ្នែកមួយនៃសៀវភៅណែនាំសមាជិករបស់លោកអ្នក។

Health Net នៅរង់ចាំជួយលោកអ្នកជានិច្ច។ ប្រសិនបើលោកអ្នកមានសំណួរ សូមហៅទូរសព្ទឥតគិតថ្លៃទៅលេខ **1-800-675-6110 (TTY: 711)**។ Health Net នៅទីនេះ 24 ម៉ោងក្នុងមួយថ្ងៃ 7 ថ្ងៃក្នុងមួយសប្តាហ៍ ឬចូលទៅកាន់គេហទំព័រលើអ៊ីនធឺណិត www.healthnet.com របស់យើងខ្ញុំ។

*Health Net Community Solutions, Inc.* (Health Net) *ជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់* Health Net, LLC. *Health Net គឺជាសញ្ញាសម្គាល់សេវាកម្មដែលបានចុះបញ្ជីរបស់ក្រុមហ៊ុន Health Net, LLC. រក្សាសិទ្ធិគ្រប់យ៉ាង។*

# 3. របៀបទទួលបានការថែទាំ

## ការបញ្ជូនបន្ត

PCP របស់អ្នក
ឬអ្នកឯកទេសដទៃទៀតនឹងផ្តល់ជូនអ្នកនូវការបញ្ជូនបន្តទៅជួបអ្នកឯក ទេសនៅក្នុងចន្លោះពេលដែលបង្ហាញនៅក្នុងផ្នែក “ការទទួលបានការថែទាំទាន់ ពេល” នៃសៀវភៅណែនាំនេះ ប្រសិនបើអ្នកត្រូវការវា។ គ្រូពេទ្យឯកទេសគឺជាគ្រូពេទ្យដែល មានការអប់រំបន្ថែមនៅក្នុងផ្នែកមួយនៃឱសថ។ PCP របស់លោកអ្នកនឹងធ្វើការជាមួយ លោកអ្នកដើម្បីជ្រើសរើសគ្រូពេទ្យឯកទេស។ ការិយាល័យ PCP របស់លោកអ្នកអាចជួយ លោកអ្នករៀបចំពេលវេលាដើម្បីទៅជួបអ្នកឯកទេស។

Post Office Box 9103
Van Nuys, California 91409-9103

សេវាផ្សេងៗទៀតដែលត្រូវការការបញ្ជូនបន្តរួមមាន នីតិវិធីក្នុងការិយាល័យ ការថតកាំរស្មីអ៊ិច ការងារមន្ទីរពិសោធន៍ និង សេវាមួយចំនួនពីគ្រូពេទ្យឯកទេស។

PCP របស់លោកអ្នកអាចផ្តល់ឲ្យលោកអ្នកនូវទម្រង់បែបបទដើម្បីយកទៅជួបគ្រូពេទ្យឯកទេស។ គ្រូពេទ្យឯកទេសនឹងបំពេញទម្រង់បែបបទ ហើយបញ្ជូនវាត្រឡប់ទៅ PCP របស់លោកអ្នក។ គ្រូពេទ្យឯកទេសនឹងព្យាបាលលោកអ្នក ដរាបណាពួកគេយល់ថាលោកអ្នកត្រូវការការព្យាបាល។

PCP របស់លោកអ្នកនឹងចាប់ផ្តើមដំណើរការបញ្ជូនបន្ត។ PCP របស់លោកអ្នកនឹងដឹង ថាតើលោកអ្នកត្រូវការអនុញ្ញាត ឬក៏លោកអ្នកអាចធ្វើការណាត់ជួបដោយផ្ទាល់បាន។ ប្រសិនបើលោកអ្នកមានសំណួរផ្សេងៗ ថាតើការថែទាំពីគ្រូពេទ្យឯកទេស ឬពីមន្ទីរពេទ្យណាមួយត្រូវការការឯកភាពដែរឬអត់នោះ លោកអ្នកអាចទូរសព្ទទៅផ្នែកសេវាបម្រើសមាជិកតាមរយៈលេខ 1-800-675-6110 (TTY 711)។ ការបញ្ជូនបន្តជាធម្មតាចំណាយពេល 5 ថ្ងៃនៃថ្ងៃធ្វើការ ដើម្បីដំណើរការ («ថ្ងៃធ្វើការ» គឺពីថ្ងៃចន្ទដល់ថ្ងៃសុក្រ) ប៉ុន្តែអាចចំណាយពេលដល់ 28 ថ្ងៃប្រតិទិន (14 ថ្ងៃគិតចាប់ពីកាលបរិច្ឆេទនៃការស្នើសុំដើមបូករួមនឹងការបន្ថែមរយៈពេល 14 ថ្ងៃ ប្រសិនបើមានការស្នើសុំបន្ថែម) ប្រសិនបើត្រូវការព័ត៌មានបន្ថែមពី PCP របស់លោកអ្នក។ ក្នុងករណីខ្លះ PCP របស់លោកអ្នកអាចស្នើសុំឲ្យមានការពន្លឿនការការបញ្ជូនរបស់លោកអ្នក។ ការបញ្ជូនដែលត្រូវបានពន្លឿន (រហ័ស) ត្រូវការពេលមិនលើសពី 72 ម៉ោងឡើយ។ សូមទូរសព្ទមកផែនការរបស់យើងខ្ញុំ ប្រសិនបើលោកអ្នកមិនបានទទួលការឆ្លើយតបនៅក្នុងរយៈពេលទាំងនេះទេ។

ប្រសិនបើលោកអ្នកមានបញ្ហាសុខភាព ដែលត្រូវការការថែទាំវេជ្ជសាស្ត្រពិសេសរយៈពេលយូរ នោះលោកអ្នកចាំបាច់ត្រូវការការបញ្ជូនបន្តជាអចិន្ត្រៃយ៍។ នេះមានន័យថា លោកអ្នកអាចទៅជួបអ្នកឯកទេសច្រើនជាងមួយដងដោយមិនចាំបាច់ទទួលការបញ្ជូនបន្តរាល់ពេលនោះទេ។

ប្រសិនបើលោកអ្នកមានបញ្ហាក្នុងការទទួលបានការបញ្ជូនបន្តអចិន្ត្រៃយ៍ ឬ ត្រូវការច្បាប់ចម្លងនៃគោលការណ៍បញ្ជូនបន្តពី Health Net សូមទាក់ទងទៅលេខ 1-800-675-6110 (TTY 711)។

លោកអ្នកមិនចាំបាច់ត្រូវការការបញ្ជូនបន្តសម្រាប់៖

- ការជួប PCP
- ការជួបពិគ្រោះផ្នែកសម្ភព/រោគស្ត្រី (OB/GYN)
- ការជួបពិគ្រោះសម្រាប់ការថែទាំបន្ទាន់ ឬគ្រាអាសន្ន
- សេវាកម្មលើបញ្ហាសំខាន់សម្រាប់មនុស្សពេញវ័យ ដូចជាការថែទាំលើការរំលោភផ្លូវភេទ
- សេវារៀបចំផែនការគ្រួសារ (ដើម្បីស្វែងយល់បន្ថែម សូមទូរសព្ទទៅការិយាល័យព័ត៌មានរៀបចំផែនការគ្រួសារ និងសេវាបញ្ជូនបន្តតាមរយៈលេខ 1-800-942-1054)
- ការធ្វើតេស្ត និងប្រឹក្សាមេរោគហ៊ីវ (អាយុចាប់ពី 12 ឆ្នាំឡើងទៅ)
- សេវាកម្មជំងឺកាមរោគ (អាយុចាប់ពី 12 ឆ្នាំឡើងទៅ)
- សេវាកម្មព្យាបាលចាប់សរសៃ (ការបញ្ជូនបន្តអាចត្រូវបានទាមទារនៅពេលផ្តល់ជូនដោយ FQHCs, RHCs និង IHCPs នៅក្រៅបណ្តាញ)
- ការវាយតម្លៃសុខភាពផ្លូវចិត្តដំបូង

health net

Post Office Box 9103
Van Nuys, California 91409-9103

- ការចាក់ម្ជុលវិទ្យាសាស្ត្រ (សេវាកម្មពីរដំបូងក្នុងមួយខែ ការណាត់ជួបបន្ថែមត្រូវការការបញ្ជូនបន្ត)
- សេវាបាទាសាស្ត្រ
- សេវាកម្មថែទាំមាត់ធ្មេញដែលមានសិទ្ធិទទួលបាន
- ការថែទាំជិតគ្រប់ខែជាប្រចាំពីវេជ្ជបណ្ឌិតដែលធ្វើការជាមួយ Health Net
- សេវាពេទ្យឆ្មបគិលានុបដ្ឋាកដែលមានការទទួលស្គាល់
- ការវាយតម្លៃសុខភាពឥរិយាបថដំបូងពីអ្នកផ្តល់សេវាសុខភាពនៃឥរិយាបថដែលធ្វើការជាមួយ Health Net

Post Office Box 9103
Van Nuys, California 91409-9103

អនីតិជនក៏អាចទទួលបានសេវាសុខភាពផ្លូវចិត្តសម្រាប់អ្នកជំងឺខាងក្រៅជាក់លាក់ សេវាកម្មលើបញ្ហាសំខាន់ៗ និងសេវាបញ្ហាប្រើប្រាស់សារធាតុញៀន ដោយគ្មានការ យល់ព្រមពីឪពុកម្តាយបានផងដែរ។ សម្រាប់ព័ត៌មានបន្ថែម សូមអាន «សេវាកម្មដែល មានការព្រមព្រៀងសម្រាប់អនីតិជន» និង «សេវាព្យាបាលបញ្ហាការប្រើប្រាស់ សារធាតុញៀន» នៅក្នុងសៀវភៅណែនាំនេះ។

## ច្បាប់សមធម៌ជំងឺមហារីករដ្ឋ California ស្តីពីការការបញ្ជូនបន្ត

**ការព្យាបាលប្រកបដោយប្រសិទ្ធភាពនៃជំងឺមហារីកស្មុគស្មាញគឺ អាស្រ័យលើកត្តា ជាច្រើនរួមទាំងការទទួលបានការវិភាគត្រឹមត្រូវ និងទទួលបានការព្យាបាល ទាន់ពេលវេលាពី អ្នកជំនាញខាងជំងឺមហារីក។**

**ប្រសិនបើអ្នកត្រូវបានគេធ្វើរោគវិនិច្ឆ័យឃើញថា មានជំងឺមហារីកស្មុគស្មាញ នោះច្បាប់ សមធម៌ជំងឺមហារីករដ្ឋ California ថ្មី អនុញ្ញាតឱ្យអ្នកស្នើសុំការបញ្ជូនបន្តពីវេជ្ជបណ្ឌិត របស់អ្នកដើម្បីទទួលបានការព្យាបាលជំងឺមហារីកជាពិសេសពីមជ្ឈមណ្ឌល ជំងឺមហារីកដែលកំណត់ដោយវិទ្យាស្ថានជាតិមហារីក (NCI) ក្នុងបណ្តាញ ទីតាំងដែល ពាក់ព័ន្ធកម្មវិធីស្រាវជ្រាវជុំសាច់មហារីកសហគមន៍ (NCORP) របស់ NCI ឬមជ្ឈមណ្ឌលមហា រីកសិក្សាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។**

**ប្រសិនបើ Health Net មិនមានមជ្ឈមណ្ឌល ជំងឺមហារីកដែលកំណត់ ដោយ NCI ក្នុងបណ្តាញទេ នោះ Health Net នឹងអនុញ្ញាត ឱ្យអ្នកស្នើសុំការបញ្ជូនបន្តដើម្បីទទួល ការព្យាបាលជំងឺមហារីកពីមជ្ឈមណ្ឌលក្រៅបណ្តាញមួយក្នុង ចំណោមមជ្ឈមណ្ឌល ទាំងនេះនៅក្នុងរដ្ឋ California ប្រសិនបើមជ្ឈមណ្ឌលមួយក្នុងចំណោម មជ្ឈមណ្ឌលនោះ នៅក្រៅបណ្តាញ ហើយ Health Net យល់ព្រមលើការទូទាត់ លុះត្រាតែអ្នកជ្រើសរើស មើលអ្នកផ្តល់សេវាព្យាបាលជំងឺមហារីកផ្សេងទៀត។**

**ប្រសិនបើអ្នកត្រូវបានធ្វើរោគវិនិច្ឆ័យថាមានជំងឺមហារីក សូមទាក់ទង Health Net ដើម្បីមើលថាតើអ្នកមានលក្ខណៈគ្រប់គ្រាន់សម្រាប់សេវាកម្មពីមជ្ឈមណ្ឌលជំងឺមហារីកមួយក្នុង ចំណោមមជ្ឈមណ្ឌលមហារីកទាំងនេះដែរឬទេ។**

Post Office Box 9103
Van Nuys, California 91409-9103

# 4. អត្ថប្រយោជន៍ និង សេវាកម្ម

## អត្ថប្រយោជន៍ Medi-Cal ដែលត្រូវបានធានារ៉ាប់រងដោយ Health Net

### សេវាអ្នកជំងឺខាងក្រៅ (អាចដើរបាន)

*ការវាយតម្លៃសុខភាពការយល់ដឹង*

Health Net ធានារ៉ាប់រងលើការវាយតម្លៃសុខភាពការយល់ដឹង ដែលប្រចាំឆ្នាំសម្រាប់ សមាជិកមានអាយុ 65 ឆ្នាំឡើង ហើយបើមិនដូច្នេះទេ មិនមានសិទ្ធិទទួល បានការវាយតម្លៃស្រដៀងគ្នាដែលជាផ្នែកនៃការទៅជួបពិគ្រោះសុខុមាលភាពប្រចាំឆ្នាំក្រោម កម្មវិធី Medicare នោះទេ។ ការវាយតម្លៃសុខភាពការយល់ដឹងពិនិត្យរកមើលសញ្ញា នៃជំងឺភ្លេចភ្លាំង ឬជំងឺវង្វេងរបស់ Alzheimer។

# សេចក្តីជូនដំណឹងស្តីពីការមិនរើសអើង

Health Net នុវត្តតាមច្បាប់ស្តីពីសិទ្ធិជនស៊ីវិលរបស់រដ្ឋ និងសហព័ន្ធ ហើយនឹងមិនរើស ើង មិនដាក់បញ្ចូលមនុស្ស ឬ ប្រព្រឹត្តិលើពួកគេមិនស្មើភាពគ្នាដោយសារតែ ភេទ ពូជសាសន៍ ពណ៌សម្បុរ សាសនា ពូជពង្ស ដើមកំណើត អត្តសញ្ញាណក្រុមជនជាតិ អាយុ ពិការភាពផ្លូវចិត្ត ពិការភាពរាងកាយ ស្ថានភាពសុខភាព ព័ត៌មានសេនេទិច ស្ថានភាពអាពាហ៍ពិពាហ៍ យេនឌ័រ អត្តសញ្ញាណយេនឌ័រ ឬទំនោរផ្លូវភេទឡើយ។

Health Net ផ្តល់ជូន៖

- ជំនួយ និងសេវាម្មឥតគិតថ្លៃដល់ជនពិការដើម្បីឲ្យទំនាក់ទំនងកាន់តែប្រសើរ ីងជាមួយយើងខ្ញុំដូចជា ្នកបកប្រែភាសាសញ្ញាដែលមានការទទួលស្គាល់ និងព័ត៌មានជាលាយលក្ខណ៍អក្សរក្នុងទម្រង់ផ្សេងទៀត (បោះពុម្ពជា ក្សរធំៗ អូឌីយ៉ូ ទម្រង់ដែលអាចចូលប្រើតាមប្រព័ន្ធអេ ិចត្រូនិក និងទម្រង់ផ្សេងៗទៀត)។
- សេវាភាសាឥតគិតថ្លៃដល់ ្នកដែលភាសាចម្បងរបស់ខ្លួនមិនមែនជាភាសា ង់គ្លេស ដូចជា អ្នកបកប្រែផ្ទាល់មាត់ដែលមានការទទួលស្គាល់ និងព័ត៌មានលាយលក្ខណ៍អក្សរជាភាសាផ្សេងៗទៀត។

ប្រសិនបើ ្នកត្រូវការសេវាកម្មទាំងនេះ ឬស្នើសុំឯកសារនេះជាទម្រង់ផ្សេងទៀត សូមទាក់ទងទៅ មជ្ឈមណ្ឌលទំនាក់ទំនង តិថិជន Health Net តាមលេខ 1-800-675-6110 (TTY: 711) 24 ម៉ោងក្នុងមួយថ្ងៃ, 7 ថ្ងៃក្នុងមួយស ្ដ ហ៍, 365 ថ្ងៃក្នុងមួយឆ្នាំ។

ប្រសិនបើ ្នកជឿជាក់ថា Health Net នខកខានក្នុងការផ្តល់សេវាកម្មទាំងនេះ ឬ នរើសអើងដោយផ្ទុយនឹងច្បាប់តាមរបៀបផ្សេងទៀតណាមួយ នោះ ្នកអាចដាក់បណ្តឹងសារទុក្ខជាមួយHealth Net តាមទូរសព្ទ ជាលាយលក្ខណ៍អក្សរ ដោយផ្ទាល់ ឬតាមប្រព័ន្ធ ិចត្រូនិក៖

- <u>តាមរយៈទូរសព្ទ៖</u> ទូរសព្ទទៅ ្នកសម្របសម្រួលសិទ្ធិជនស៊ីវិលរបស់ Health Net (Health Net Civil Rights Coordinator) តាមលេខ 1-866-458-2208 (TTY: 711) ពីថ្ងៃចន្ទដល់ថ្ងៃសុក្រ ចាប់ពីម៉ោង 8 ព្រឹក ដល់ម៉ោង 5 ល្ងាច។
- <u>ជាលាយលក្ខណ៍អក្សរ៖</u> បំពេញទម្រង់បែបបទពាក្យបណ្តឹង ឬសរសេរលិខិត ហើយផ្ញើទៅ Health Net Civil Rights Coordinator, P.O. Box 9103, Van Nuys, CA 91409-9103>។
- <u>ដោយផ្ទាល់៖</u> ទៅកាន់ការិយាល័យវេជ្ជបណ្ឌិតរបស់អ្នក ឬ Health Net ហើយនិយាយថា ្នកចង់ដាក់បណ្តឹងសារទុក្ខ។
- <u>តាមប្រព័ន្ធអេ ិចត្រូនិក៖</u> សូមចូលទៅគេហទំព័ររបស់ Health Net តាមរយៈ www.healthnet.com

ក៏អាចដាក់ពាក្យបណ្តឹងស្តីពីសិទ្ធិជនស៊ីវិលជាមួយក្រសួងសេវាថែទាំសុខភាពរដ្ឋ California, ការិយាល័យសិទ្ធិជនស៊ីវិល តាមរយៈទូរសព្ទ, ជាលាយលក្ខណ៍អក្សរ ឬតាមប្រព័ន្ធអេ ិចត្រូនិក៖

- <u>តាមរយៈទូរសព្ទ៖</u> សូមទូរសព្ទទៅលេខ 916-440-7370 ។ ប្រសិនបើអ្នកមិនអាចនិយាយ ឬស្តាប់មិនសូវ នល្អ សូមទូរសព្ទទៅ 711 ។
- <u>ជាលាយលក្ខណ៍អក្សរ៖</u> បំពេញទម្រង់បែបបទពាក្យបណ្តឹង ឬសរសេរលិខិត ហើយផ្ញើទៅ នុប្រធានការិយាល័យសិទ្ធិជនស៊ីវិល ក្រសួងសេវាថែទាំសុខភាព ការិយាល័យសិទ្ធិជនស៊ីវិល, P.O. Box 997413, MS 0009, Sacramento, CA 95899-7413 ។
  ទម្រង់បែបបទពាក្យបណ្តឹងមាននៅ http://www.dhcs.ca.gov/Pages/Language_Access.aspx
- <u>តាមប្រព័ន្ធអេ ិចត្រូនិក៖</u> ផ្ញើអ៊ីមែលទៅ CivilRights@dhcs.ca.gov

ប្រសិនបើ កជឿជាក់ថា អ្នកត្រូវបានគេរើសអើងដោយសារតែពូជសាសន៍ ពណ៌សម្បុរ ដើមកំណើត អាយុ ពិការភាព ឬភេទ នោះ ក៏អាចដាក់ពាក្យបណ្តឹងស្តីពីសិទ្ធិជនស៊ីវិលជាមួយក្រសួងសុខាភិបាល និងសេវាកម្មមនុស្សជាតិសហរដ្ឋអាមេរិក ការិយាល័យសិទ្ធិជនស៊ីវិលតាមរយៈទូរសព្ទ, ជាលាយលក្ខណ៍អក្សរ ឬតាមប្រព័ន្ធអេ ិចត្រូនិក៖

- <u>តាមរយៈទូរសព្ទ៖</u> 1-800-368-1019 (TDD: 1-800-537-7697)
- <u>ជាលាយលក្ខណ៍អក្សរ៖</u> បំពេញទម្រង់បែបបទពាក្យបណ្តឹង ឬផ្ញើលិខិតទៅក្រសួងសុខាភិបាល និងសេវាកម្មមនុស្សជាតិសហរដ្ឋអាមេរិក, 200 Independence Avenue SW, Room 509F, HHH Building, Washington, DC 20201
  ទម្រង់បែបបទពាក្យបណ្តឹងមាននៅ http://www.hhs.gov/ocr/office/file/index.html
- <u>តាមប្រព័ន្ធអេ ិចត្រូនិក៖</u> សូមចូលទៅផតថលការិយាល័យនៃពាក្យបណ្តឹងសិទ្ធិជនស៊ីវិលតាមរយៈ https://ocrportal.hhs.gov/ocr/portal/lobby.jsf

**English:** If you, or someone you are helping, need language services, call 1-800-675-6110 (TTY: 711). Aids and services for people with disabilities, like accessible PDF and large print documents, are also available. These services are at no cost to you.

**Arabic:** إذا كنت أنت أو أي شخص تقوم بمساعدته، بحاجة إلى الخدمات اللغوية، فاتصل بالرقم 1-800-675-6110 (TTY: 711) تتوفر أيضاً المساعدات والخدمات للأشخاص ذوي الإعاقة، مثل الملفات المنقولة (PDF) التي يمكن الوصول إليها والمستندات المطبوعة الكبيرة. تتوفر هذه الخدمات بدون تكلفة بالنسبة لك.

**Armenian:** Եթե դուք կամ որևէ մեկը, ում դուք օգնում եք, ունեն լեզվական օգնության կարիք, զանգահարեք 1-800-675-6110 (TTY՝ 711): Հաշմանդամություն ունեցող մարդկանց համար հասանելի են օգնություն և ծառայություններ, ինչպես օրինակ՝ մատչելի PDF և մեծ տպագրությամբ փաստաթղթեր: Այս ծառայությունները ձեզ համար անվճար են:

**Cambodian:** ប្រសិនបើអ្នក ឬនរណាម្នាក់ដែលអ្នកកំពុងជួយ ត្រូវការសេវាផ្នែកភាសា សូមទូរសព្ទទៅលេខ 1-800-675-6110 (TTY: 711)។ ជំនួយ និងសេវាកម្មផ្សេងៗសម្រាប់អ្នកដែលពិការ ដូចជាទម្រង់ PDF សម្រាប់អ្នកពិការ និងឯកសារព្រីនជាអក្សរខ្នាតធំក៏មានផ្តល់ជូនផងដែរ។ សេវាកម្មទាំងនេះត្រូវបានផ្តល់ជូនអ្នកដោយមិនគិតថ្លៃ។

**Chinese:** 如果您或您正在幫助的其他人需要語言服務，請致電1-800-675-6110 (TTY: 711)。另外，還為殘疾人士提供輔助和服務，例如易於讀取的 PDF 和大字版文件。這些服務對您免費提供。

**Farsi:** اگر شما یا هر فرد دیگری که به او کمک می‌کنید نیاز به خدمات زبانی دارد، با شمارهٔ 1-800-675-6110 (TTY: 711) تماس بگیرید. کمک‌ها و خدماتی مانند مدارک با چاپ درشت و PDF دسترس‌پذیر نیز برای معلولان قابل عرضه است. این خدمات هزینه‌ای برای شما نخواهد داشت.

**Hindi:** यदि आपको, या जिसकी आप मदद कर रहे हैं उसे, भाषा सेवाएँ चाहिए, तो कॉल करें 1-800-675-6110 (TTY: 711)। विकलांग लोगों के लिए सहायता और सेवाएं, जैसे सुलभ PDF और बड़े प्रिंट वाले दस्तावेज़, भी उपलब्ध हैं। ये सेवाएँ आपके लिए मुफ़्त उपलब्ध हैं।

**Hmong:** Yog hais tias koj, los sis ib tus neeg twg uas koj tab tom pab nws, xav tau cov kev pab cuam txhais lus, hu rau 1-800-675-6110 (TTY: 711). Tsis tas li ntawd, peb kuj tseem muaj cov khoom siv pab thiab cov kev pab cuam rau cov neeg xiam oob qhab tib si, xws li cov ntaub ntawv PDF uas tuaj yeem nkag cuag tau yooj yim thiab cov ntaub ntawv luam tawm uas pom tus niam ntawv loj. Cov kev pab cuam no yog muaj pab yam tsis xam nqi dab tsi rau koj them li.

**Japanese:** ご自身またはご自身がサポートしている方が言語サービスを必要とする場合は、1-800-675-6110 (TTY: 711)までお問い合わせください。障がいをお持ちの方のために、アクセシブルなPDFや大きな文字で書かれたドキュメントなどの補助・サービスも提供しています。これらのサービスは無料で提供されています。

**Korean:** 귀하 또는 귀하가 도와주고 있는 분이 언어 서비스가 필요하시면 1-800-675-6110 (TTY: 711) 번으로 연락해 주십시오. 장애가 있는 분들에게 보조 자료 및 서비스(예: 액세스 가능한 PDF 및 대형 활자 인쇄본)도 제공됩니다. 이 서비스는 무료로 이용하실 수 있습니다.

**Laotian:** ຖ້າທ່ານ, ຫຼື ບຸກຄົນໃດໜຶ່ງທີ່ທ່ານກໍາລັງຊ່ວຍເຫຼືອ, ຕ້ອງການບໍລິການແປພາສາ, ໂທ 1-800-675-6110 (TTY: 711). ນອກນັ້ນ, ພວກເຮົາຍັງມີອຸປະກອນຊ່ວຍເຫຼືອ ແລະ ການບໍລິການສໍາລັບຄົນພິການອີກດ້ວຍ, ເຊັ່ນ ເອກະສານ PDF ທີ່ສາມາດເຂົ້າເຖິງໄດ້ສະດວກ ແລະ ເອກະສານພິມຂະໜາດໃຫຍ່. ການບໍລິການເຫຼົ່ານີ້ແມ່ນມີໄວ້ຊ່ວຍເຫຼືອທ່ານໂດຍບໍ່ໄດ້ເສຍຄ່າໃດໆ.

**Mien:** Da’faanh Meih, Fai Heuc Meih Haih Tengx, Oix Janx-kaeqv waac gong, Heuc 1-800-675-6110 (TTY: 711). JomcCaux gong Bun Yangh mienh Caux mv fungc, Oix dongh eix PDF Caux Bunh Fiev dimc, Haih yaac kungx nyei. Deix gong Haih buatc Yietc liuz maiv jaax-zinh Bieqc Meih.

**Punjabi:** ਜੇ ਤੁਹਾਨੂੰ, ਜਾਂ ਜਿਸ ਦੀ ਤੁਸੀਂ ਮਦਦ ਕਰ ਰਹੇ ਹੋ, ਨੂੰ ਭਾਸ਼ਾ ਸੇਵਾਵਾਂ ਦੀ ਜ਼ਰੂਰਤ ਹੈ, ਤਾਂ 1-800-675-6110 (TTY: 711) 'ਤੇ ਕਾਲ ਕਰੋ। ਅਪਾਹਜ ਲੋਕਾਂ ਲਈ ਸਹਾਇਤਾ ਅਤੇ ਸੇਵਾਵਾਂ, ਜਿਵੇਂ ਕਿ ਪਹੁੰਚਯੋਗ PDF ਅਤੇ ਵੱਡੇ ਪ੍ਰਿੰਟ ਵਾਲੇ ਦਸਤਾਵੇਜ਼, ਵੀ ਉਪਲਬਧ ਹਨ। ਇਹ ਸੇਵਾਵਾਂ ਤੁਹਾਡੇ ਲਈ ਮੁਫ਼ਤ ਹਨ।

**Russian:** Если вам или человеку, которому вы помогаете, необходимы услуги перевода, звоните по телефону 1-800-675-6110 (TTY: 711). Кроме того, мы предоставляем материалы и услуги для людей с ограниченными возможностями, например документы в специальном формате PDF или напечатанные крупным шрифтом. Эти услуги предоставляются бесплатно.

**Spanish:** Si usted o la persona a quien ayuda necesita servicios de idiomas, comuníquese al 1 800-675-6110 (TTY: 711). También hay herramientas y servicios disponibles para personas con discapacidad, como documentos en letra grande y en archivos PDF accesibles. Estos servicios no tienen ningún costo para usted.

**Tagalog:** Kung ikaw o ang taong tinutulungan mo ay kailangan ng mga serbisyo sa wika, tumawag sa 1-800-675-6110 (TTY: 711). Makakakuha rin ng mga tulong at serbisyo para sa mga taong may mga kapansanan, tulad ng naa-access na PDF at mga dokumentong malaking print. Wala kang babayaran para sa mga serbisyong ito.

**Thai:** หากคุณหรือคนที่คุณช่วยเหลือ ต้องการบริการด้านภาษา โทร 1-800-675-6110 (TTY: 711) นอกจากนี้ยังมีความช่วยเหลือและบริการสำหรับผู้ทุพพลภาพ เช่น PDF ที่เข้าถึงได้และเอกสารที่พิมพ์ขนาดใหญ่ บริการเหล่านี้ไม่มีค่าใช้จ่ายสำหรับคุณ

**Ukrainian:** Якщо вам або людині, якій ви допомагаєте, потрібні послуги перекладу, телефонуйте на номер 1-800-675-6110 (TTY: 711). Ми також надаємо матеріали та послуги для людей з обмеженими можливостями, як-от документи в спеціальному форматі PDF або надруковані великим шрифтом. Ці послуги для вас безкоштовні.

**Vietnamese:** Nếu quý vị hoặc ai đó mà quý vị đang giúp đỡ cần dịch vụ ngôn ngữ, hãy gọi 1-800-675-6110 (TTY: 711). Chúng tôi cũng có sẵn các trợ giúp và dịch vụ dành cho người khuyết tật, như tài liệu dạng bản in khổ lớn và PDF có thể tiếp cận được. Quý vị được nhận các dịch vụ này miễn phí.